**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ៦៦៧/១៧ **គ.ជ.ប**

# សេចក្តីជូនដំណឹង

- យោងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៧០៦/៣០៥ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងព្រះរាជក្រមលេខ នស/រកម/០១១២/០០៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការកំណត់អាសនៈរដ្ឋសភាសម្រាប់នីតិកាលទី ៥
- យោងសេចក្តីសម្រេចលេខ ២១ សសរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជូនដំណឹងជាសាធារណៈដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសជ្រាបថា កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ ត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ខាងមុខនេះ។

ចំនួនអាសនៈរដ្ឋសភាសម្រាប់នីតិកាលទី ៥ ត្រូវបានកំណត់ត្រឹមមួយរយម្ភៃបី (១២៣)។

ចំនួនអាសនៈនេះ ត្រូវបានកំណត់បែងចែកទៅតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ដូចខាងក្រោមនេះ ៖

| លេខកូដ | មណ្ឌលរាជធានី ខេត្ត | ចំនួនអាសនៈ |
|---|---|---|
| ០១ | បន្ទាយមានជ័យ | ៦ |
| ០២ | បាត់ដំបង | ៨ |
| ០៣ | កំពង់ចាម | ១៨ |
| ០៤ | កំពង់ឆ្នាំង | ៤ |

| លេខកូដ | មណ្ឌលរាជធានី ខេត្ត | ចំនួនអាសនៈ |
|---|---|---|
| ០៥ | កំពង់ស្ពឺ | ៦ |
| ០៦ | កំពង់ធំ | ៦ |
| ០៧ | កំពត | ៦ |
| ០៨ | កណ្តាល | ១១ |
| ០៩ | កោះកុង | ១ |
| ១០ | ក្រចេះ | ៣ |
| ១១ | មណ្ឌលគិរី | ១ |
| ១២ | ភ្នំពេញ | ១២ |
| ១៣ | ព្រះវិហារ | ១ |
| ១៤ | ព្រៃវែង | ១១ |
| ១៥ | ពោធិ៍សាត់ | ៤ |
| ១៦ | រតនគិរី | ១ |
| ១៧ | សៀមរាប | ៦ |
| ១៨ | ព្រះសីហនុ | ១ |
| ១៩ | ស្ទឹងត្រែង | ១ |
| ២០ | ស្វាយរៀង | ៥ |
| ២១ | តាកែវ | ៨ |
| ២២ | កែប | ១ |
| ២៣ | ប៉ៃលិន | ១ |
| ២៤ | ឧត្តរមានជ័យ | ១ |
| | **សរុប** | ១២៣ |

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេសជ្រាបជាព័ត៌មាន និង សហការជម្រុញឱ្យដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ សម្រេចបានជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១២

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ឹម សួស្តី